# STREAM
# គោលនយោបាយសង្ខេប

www.streaminitiative.org

លេខ ១

ខែ កុម្ភៈ ឆ្នាំ ២០០៥

សង្ខេប

### តើអត្ថបទនេះពិព័ណ៌នាអំពីអ្វី?

ប្រជាជនឯកភាពចំពោះការផ្លាស់ប្តូរគោលនយោបាយ

### សូមអានអត្ថបទនេះ ប្រសិនបើ...

...លោកអ្នកចង់ផ្លាស់ប្តូរគោលនយោបាយ ។

### ការផ្លាស់ប្តូរនេះពាក់ព័ន្ធនឹង :

- ការយល់ដឹងពីបរិប័ទនៃជីវភាពរស់នៅដែលជាគោលនយោបាយមួយអាចអនុវត្តទៅបាន ។
- ប្រមូលផ្តុំពីគ្រប់អ្នកអនុវត្តគោលនយោបាយនូវរាល់មតិយោបល់ស្តីពីគោលនយោបាយបច្ចុប្បន្ន និង គ្រប់អនុសាសន៍សម្រាប់ធ្វើការផ្លាស់ប្តូរគោលនយោបាយ ។
- ផ្លាស់ប្តូរនូវរាល់គំនិងតាមរយៈការសម្តែងល្ខោន លំហាត់សិក្សា សិក្ខាសាលា និង រាល់មេរៀនដែលទទួលបានពីការគ្រប់ចូលរួមនានា ។
- កសាងមតិរួមដើម្បីធ្វើការផ្លាស់ប្តូរគោលនយោបាយ ។

" កុំគិតពីឋានានុក្រម ក្នុងការធ្វើសេចក្តីសម្រេចចិត្ត "

" ការសម្របសម្រួល ការចូលរួមទទួលយកនូវធនធានដែលមាន និង មតិស្ថាបនានានា "

" ធ្វើការប្រៀបធៀបនូវរាល់ការឆ្លើយតប ការត្រួតពិនិត្យនូវរាល់ការព្រមព្រៀងគ្នា និង ការឯកភាពលើការសម្រេចចិត្ត "

ទាំងនេះជាការងារដែលបានបំពេញជាផ្លូវការ និង ក្រៅផ្លូវការដែលបានបំពេញដោយក្រុមការងារតូច ឬធំ ។

អត្ថបទនេះជួយប្រជាជនឱ្យបានមានមតិចូលរួមលើការបង្កើតគោលនយោបាយ និង ធ្វើឱ្យអ្នកអនុវត្តគោលនយោបាយទាំងនោះ ចូលរួមផ្តល់នូវការពន្យល់បកស្រាយ និង មតិយោបល់ដោយសេរី ។

អត្ថបទនេះផ្តល់ឱ្យផងដែរនូវជម្រើសផ្លាស់ប្តូរគោលនយោបាយអត្ថិភាពសមស្របលើរាល់ការធ្វើសេចក្តីសម្រេចចិត្ត ។

សេចក្តីសង្ខេបស្តីពី....

# ការកសាងមតិរួម

...តែ ២ ទំព័រ ឬតិចជាង

**ប្រសិនបើលោកអ្នកអាចធ្វើអ្វីមួយដើម្បីរួមចំណែកដល់គោលនយោបាយសង្ខេបនេះ " this Policy Brief" សូមចូលរួមធ្វើ...**

**ជួយសម្រួលដល់អ្នកអនុវត្តគោលនយោបាយ ដើម្បីឱ្យគាត់ចូលរួមផ្តល់នូវអនុសាសន៍ដល់ការផ្លាស់ប្តូរគោល-នយោបាយ និង កសាងមតិរួមពីគ្រប់ភាគីចូលរួមដើម្បីបង្កើត និង អនុវត្តគោលនយោបាយ ។**

## សេចក្តីសង្ខេប....

ដើម្បីបង្កើតគោលនយោបាយឱ្យបានល្អ យើងគប្បីស្វែងយល់ឱ្យបានច្បាស់ពីបរិប័ទនៃជីវភាពរស់នៅដែលគោលនយោបាយអាចអនុវត្តទៅបាន ។

វាមិនងាយស្រួល ឬប្រញាប់ប្រញាល់ពេកឡើយ ដើម្បីធ្វើឱ្យយល់បានពីធនធានដែលប្រជាជនមាន និង ទទួលបានតាមគ្រប់រូប-ភាព ។ ភាពងាយទទួលរងគ្រោះ និង យុទ្ធសាស្ត្រសមស្របរបស់ពួកគាត់ និង គ្រប់រូបភាពដែលគោលនយោបាយទាំងនោះអាចជួយដល់គោលបំណងនៃការបង្កើនជីវភាពរស់នៅរបស់ពួកគាត់ឱ្យបានកាន់តែប្រសើរឡើង ។ ការយល់ដឹងទាំងនេះនឹងទទួលបានមកពីប្រជាជនដែលជាអ្នកអនុវត្តនូវគោលនយោបាយ ។ ការងារនេះមានរួមបញ្ចូលនូវរាល់បច្ចេកទេស គ្រប់រូបភាពនៃការបណ្តុះ-បណ្តាល ដើម្បីជួយយើងទាំងអស់គ្នាឱ្យអាចកសាងបាននូវទំនាក់ទំនងក្នុងការជឿទុកចិត្តគ្នា និង ផលចំណេញដែលទទួលបានតាមរយៈការយល់ដឹង ។

ក្នុងពេលជាមួយគ្នានេះដែរ ការយល់បានពីការរស់នៅរបស់ប្រជាជន ដែលយើងអាចរៀនសូត្របានពីពួកគាត់តាមរយៈបទ-ពិសោធន៍នៃការអនុវត្តគោលនយោបាយរបស់ពួកគាត់ និង ការប្រមូលផ្តុំបាននូវរាល់មតិយោបល់ និង អនុសាសន៍របស់ពួកគាត់សម្រាប់ធ្វើការកែប្រែគោលនយោបាយ ។

អ្នករៀបចំ និង អ្នកបង្កើតគោលនយោបាយគឺតែងតែទទួលបាននូវទិសដៅដែលជាគោលនយោបាយរបស់សហគមន៍មូលដ្ឋានដើម្បីជួយដល់សហគមន៍របស់ពួកគាត់ ។ អាចមានឧបសគ្គជាច្រើនលើការបកស្រាយ វប្បធម៌ និង សេដ្ឋកិច្ចសង្គមដល់គ្រប់សហគមន៍ ។ មានយន្តការជាច្រើនសម្រាប់ផ្លាស់ប្តូរព័ត៌មានគ្នាឱ្យបានទាន់ពេលវេលា ឧទាហរណ៍ គាំទ្រកសិករ ឬអ្នកនេសាទដើម្បីធ្វើយ៉ាងណាឱ្យជីវភាពរស់នៅរបស់ពួកគាត់បានកាន់តែប្រសើរឡើង ឬតាមរយៈសកម្មភាពការងារជាសាធារណៈ និង លំហាត់សិក្សា បន្ទាប់មក សម្តែង ឬបង្ហាញនូវបទពិសោធន៍ទាំងនោះ និង លើកទឹកចិត្តឱ្យមានការបញ្ចេញមតិឱ្យបានច្បាស់លាស់នូវគ្រប់អង្គសិក្ខាសាលាស្តីពីគោលនយោបាយ ដោយត្រូវធ្វើការផ្លាស់ប្តូរនូវរាល់មេរៀនដែលទទួលបានពីការចូលរួមនានាឱ្យបានផុលផុស ។

ចូល ទៅដល់សហគមន៍ ហើយក្តាប់ឱ្យបានច្បាស់ពីបរិប័ទនៃជីវភាពរស់នៅដែលគោលនយោបាយអាចអនុវត្តទៅបាន ។

- ចូលទៅដល់សហគមន៍ ហើយក្តាប់ឱ្យបានច្បាស់ពីបរិប័ទនៃជីវភាពរស់នៅដែលគោលនយោបាយអាចអនុវត្តទៅបាន
- ប្រមូលផ្តុំពីគ្រប់អ្នកអនុវត្តគោលនយោបាយនូវរាល់មតិយោបល់ស្តីពីគោលនយោបាយបច្ចុប្បន្ន និង គ្រប់អនុសាសន៍សម្រាប់ធ្វើការផ្លាស់ប្តូរគោលនយោបាយ និង
- ផ្លាស់ប្តូរនូវរាល់គំនិងតាមរយៈការសម្តែងល្ខោន លំហាត់សិក្សា សិក្ខាសាលា និង រាល់មេរៀនដែលទទួលបានពីគ្រប់ការចូលរួមនានា ។

→ ទាំងនេះជួយយើងឱ្យយល់បានពីបញ្ហាជាគន្លឹះមួយចំនួននិងបរិប័ទនៃគោលនយោបាយដែលអាចអនុវត្តទៅបាន គុណវិបត្តិរបស់គោលនយោបាយនោះ និង រាល់អនុសាសន៍សម្រាប់ធ្វើការផ្លាស់ប្តូរគោលនយោបាយ ។

## សេចក្តីសង្ខេបស្តីពី... ការកសាងមតិរួមសម្រាប់ធ្វើការផ្លាស់ប្តូរគោលនយោបាយ

ដើម្បីប្រែក្លាយអនុសាសន៍ទៅជាការសម្រេចចិត្តលើគោលនយោបាយ ត្រូវឱ្យមានការពិភាក្សា និង ការកសាងមតិរួមមួយ ។ គ្រប់ដំណើរការនៃការកសាងមតិរួមបានជួយដល់ការធ្វើសេចក្តីសម្រេចចិត្តដោយស្ថិតក្នុងបរិយាកាសយោគយល់គ្នា និងទទួលយកបាន ឬការសម្រេចចិត្តដែលប៉ះពាល់ដល់កត្តានានាដោយការប្រឆាំងតវ៉ា ថែរក្សានូវផលប្រយោជន៍ដល់ក្រុមអ្នកធ្វើការសម្រេចចិត្តដើម្បីជៀសពីការកំណត់ព្រំដែនទាំងឡាយ ។

### កសាងមតិរួមដើម្បីធ្វើការផ្លាស់ប្តូរ (គោលនយោបាយ)

**កោះប្រជុំក្រុម**អ្នកអនុវត្ត និង អ្នកបង្កើតគោលនយោបាយ (ក្នុងកំរិតថ្នាក់មូលដ្ឋាន ខេត្ត-ក្រុង និង ថ្នាក់ជាតិ) ។ សមាជិកក្រុមនីមួយៗគប្បីត្រូវស្គាល់សមាជិកនានារបស់ក្រុម ទោះបីធ្វើការនៅកន្លែងផ្សេងគ្នាក៏ដោយ តែត្រូវផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមក និង ដាក់ចេញជាជម្រើសដោយមិនបាច់ចេញមុខ តាមរយៈអ្នកសម្រុះសម្រួល ។

អ្នកសម្រុះសម្រួលផ្តល់**ព័ត៌មានស្តីអំពីបរិបទ** និង **ជម្រើសសម្រាប់ផ្លាស់ប្តូរគោលនយោបាយ** (ពីគ្រប់អ្នកផ្តល់សេវាគោលនយោបាយ) ឱ្យសិក្ខាកាមនីមួយៗធ្វើការចាត់ថ្នាក់នូវជម្រើសនៃ**ការផ្លាស់ប្តូរគោលនយោបាយ** ប្រមូលប្រៀបធៀបនូវរាល់ចម្លើយ និង បញ្ជូននូវរាល់ជម្រើសដោយមិនបាច់ចេញមុខដល់សមាជិកក្រុមគ្រប់រូប ។ ពេលនេះគ្រប់សិក្ខាកាមដែលបានចូលរួមក្នុងដំណើរការកសាងមតិរួមទាំងអស់អាចយល់ព្រម ឬមិនយល់ព្រមដោយសេរី និង ដោយគំនិតវិភាគផ្ទាល់ និង លើកទឹកចិត្តគ្នាទៅវិញទៅមកផងដែរដើម្បីផ្លាស់ប្តូរនូវទស្សនៈរបស់ពួកគាត់ ។ អ្នកសម្រុះសម្រួលត្រូវលើកបង្ហាញពីចំណុចសំខាន់ៗនូវរាល់មតិរួមដែលបានសម្រេចចេញថ្មីៗ ហើយ សិក្ខាកាមឯករាជ្យមួយចំនួនជាអ្នកសម្រេចនូវមតិឯកភាពនោះ ឬលើកសំណើឱ្យមានការជជែកវែកញែកបន្ថែមទៀតនូវហេតុផលដែលអ្នកដ៏ទៃហ៊ានធ្វើការផ្លាស់ប្តូរមតិរបស់អ្នកផ្សេង ។

→ អត្ថបទនេះជួយដល់សមាជិកក្រុមទាំងអស់ឱ្យបញ្ចេញនូវទស្សនៈផ្ទាល់ខ្លួនដោយសេរី និង បញ្ចេញជាទស្សនៈរិះគន់ស្ថាបនាដោយកំបាំងមុខ ដោយជៀសវាងនូវការគាបសង្កត់ពីសមាជិកណាម្នាក់នៃក្រុម និងមន្ត្រីជាន់ខ្ពស់ណាឡើយ ។

**តាមរយៈការលើកឡើងជាបន្តបន្ទាប់** ជាទូទៅមិនឱ្យលើស ៤ ដង **ដែលម្នាក់ៗអាចចូលរួមមតិយោបល់នៃការគិតពិចារណាខ**

→ ទទួលបាននូវអនុសាសន៍ជាច្រើនសម្រាប់ធ្វើការផ្លាស់ប្តូរពីសហគមន៍ ដោយផ្តល់ឱ្យ**សមាជិកសហគមន៍ទាំងអស់បញ្ចេញមតិ** សម្រុះសម្រួល លើកឡើងដោយកំបាំងមុខ និង ត្រួតពិនិត្យនូវរាល់មតិរិះគន់ស្ថាបនា ដែលបានផ្តល់ដល់អ្នកបង្កើតគោលនយោបាយ និង អ្នកអនុវត្តដើម្បីមានឱកាសចូលរួមគ្រប់ពេលវេលា ។

អត្ថបទនេះផ្តល់ឱ្យយ៉ាងច្បាស់លាស់នូវ**ជម្រើសនៃការផ្លាស់ប្តូរគោលនយោបាយជាអត្ថិភាព** — ដែលទទួលបានមកពីអ្នកទទួលយកគោលនយោបាយ និង មានការយកល់ព្រមពីអ្នកធ្វើគោលនយោបាយ និង អ្នកអនុវត្ត — ដោយផ្អែកលើមូលដ្ឋាននៃការសម្រេចចិត្តចំពោះការផ្លាស់ប្តូរគោលនយោបាយ ។

**ភ្ជាប់គ្នាទៅនឹងប្រភពព័ត៌មាន និង ឯកសារដទៃទៀតដែលទាក់ទងទៅនឹងប្រធានបទខាងលើនេះ :**

- **R ៨.១០០ គោលនយោបាយតាមដានកែលំអ ស្តីពី ការផ្តល់នូវសេវាកម្មវារីវប្បកម្មដល់ប្រជាជនក្រីក្រ** មាន ១២ របាយការណ៍ (ISBN ៩៧៤-៧៣១៣-៦៣-៤) http://www.streaminitiative.org/Library/India/india.html
- **R ៨.៣៣៤ ជម្រុញនូវគ្រប់មេរៀននៃ R ៨.១០០ ដែលជាគោលនយោបាយផ្តោតចំពោះប្រជាជនក្រីក្រ ដោយធ្វើការជាមួយនឹងអ្នកអនុវត្តគោលនយោបាយបង្គោលៗនៅក្នុងប្រទេសឥណ្ឌា** មាន ៨ របាយការណ៍ http://www.streaminitiative.org/Library/pdf/pdf-india/StakeholdersMeeting.pdf

**តើគោលនយោបាយទាំងនេះចេញមកពីណា?**

រាល់សេរីនៃគោលនយោបាយសង្ខេប គឺរៀបចំឡើងដោយ "**ការគាំទ្រដល់ការគ្រប់គ្រងប្រភពធនធានវារីជាតិក្នុងតំបន់**" **the Support to Regional Aquatic Resources Management (STREAM)** ដែលផ្តួចផ្តើមដោយបណ្តាញមជ្ឈមណ្ឌលវារីវប្បកម្មនៅអាស៊ីប៉ាស៊ីហ្វិច **(NACA)** ។

គោលនយោបាយសង្ខេបលេខ ១ បរិយាយពីបទពិសោធន៍របស់កសិករ អ្នកនេសាទ អាជ្ញាធរមូលដ្ឋាន សង្កាត់ ស្រុក រដ្ឋ និង រដ្ឋាភិបាលថ្នាក់ជាតិ អង្គការមិនមែនរដ្ឋាភិបាល ដែលគាំទ្រដោយរដ្ឋាភិបាលអង់គ្លេស DFID Natural Resources Systems Program project R ៨.១០០ " **គោលនយោបាយតាមដានកែលំអ ស្តីពី ការផ្តល់នូវសេវាកម្មវារីវប្បកម្មដល់ប្រជាជនក្រីក្រ**" ដែលចាប់ផ្តើមអនុវត្តគម្រោងតាំងពីខែ មីនា ឆ្នាំ ២០០២ ដល់ខែ មេសា ឆ្នាំ ២០០៣ ដើម្បីស្វែងឱ្យឃើញ សាកល្បង និង ជម្រុញនូវរាល់យន្តការសម្រាប់នាំមកនូវសេវាកម្មជនបទឱ្យកាន់តែល្អប្រសើរ ដើម្បីការអភិវឌ្ឍន៍ជីវភាពរស់នៅតាមជនបទ ជាមួយនឹងការស្វែងចេញឱ្យឃើញនូវគ្រប់សេវាកម្មទាំងអស់ក្នុងការជួយដល់វិស័យវារីវប្បកម្ម ។ ព័ត៌មានបន្ថែមសូមស្រាវជ្រាវតាមគេហទំព័រ www.streaminitiative.org/Library/India/india.html ឬទាក់ទង STREAM, NACA មហាវិថី ស៊ូវ៉ាវ៉ាឌី បរិវេណ នាយកដ្ឋានជលផល សាកលវិទ្យាល័យ កាសេតសាទ សង្កាត់ ឡាយ៉ាវ ខ័ណ្ឌ ចាទូចាក ទីក្រុង បាងកក ១០៩០០ ប្រទេស ថៃឡង់ដ៍ ទូរសារលេខ (៦៦២) ៥៦១-១៧២៧, ទូរស័ព្ទលេខ (៦៦២)៥៦១-១៧២៨ ។